# គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា
THE BAR ASSOCIATION OF THE KINGDOM OF CAMBODIA

## មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី
LAWYERS TRAINING CENTER

មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី ត្រូវបានបង្កើតឡើងតាំងពីឆ្នាំ ២០០១ តាមអនុក្រឹត្យលេខ ៩៣អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០១ ដោយកាលនោះមានឈ្មោះថា *មជ្ឈមណ្ឌលបណ្តុះបណ្តាលសុក្រឹតការ និង វិជ្ជាជីវៈមេធាវី* លុះក្រោយមកផ្លាស់ប្តូរឈ្មោះដូចសព្វថ្ងៃ តាមអនុក្រឹត្យលេខ១៣០ អនក្រ.បក ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៨ ។ មជ្ឈមណ្ឌលបានបណ្តុះបណ្តាលសិស្សមេធាវីជាច្រើនជំនាន់មកហើយ និង បានធ្វើឱ្យកំណើនមេធាវីក្នុងការប្រកបវិជ្ជាជីវៈមេធាវីកើនច្រើនឡើងៗ សំដៅបង្កើន និងជំរុញការអនុវត្តច្បាប់នៅកម្ពុជារីកចំរើនតាមគោល នយោបាយចតុកោណរបស់រាជរដ្ឋាភិបាល ហើយធ្វើឱ្យជាតិ និងអន្តរជាតិកាន់តែកត់សំគាល់ ជាទីមោទនភាព។

បច្ចុប្បន្នមជ្ឈមណ្ឌលបាន និងកំពុងធ្វើការរៀបចំកែរទំរង់ ទាំងការគ្រប់គ្រង ដឹកនាំ រដ្ឋបាល និងបច្ចេកទេសជាច្រើន ។

### អគ្គការលេខមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី





*អាគារ លេខ១៧ (ក្នុងរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ជាន់ទី៣)*
*ផ្លូវ៤៦៦ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ*
*ទូរសព្ទ – ទូរសារ: :៨៥៥–២៣ ៧២៦ ២៤១*
*អ៊ីមែល : LTC@online.com.kh*


## សង្ខេបកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី

យោងតាម សេចក្តីសំរេចរបស់គណៈមេធាវីលេខ ១៤០/សសកម/០៨ ចុះថ្ងៃទី២៤-១២-២០០៨ និងលិខិតជូនដំណឹងរបស់គណៈមេធាវីលេខ ៧០៣ ចុះថ្ងៃទី៣១-១២-២០០៨ ឃើញថា សំរាប់ការបណ្តុះបណ្តាលសិស្សមេធាវីជំនាន់**១០** ឆ្នាំសិក្សា ២០០៩-២០១១ ត្រូវបានកែប្រែមកសិក្សារយៈពេល **២**ឆ្នាំ ដោយត្រូវសិក្សានៅមជ្ឈមណ្ឌល**៩**ខែ លើមុខវិជ្ជាចំបងសំខាន់ៗ សិក្សាកម្មវិធីអនុវត្តជាក់ស្តែងនៅមណ្ឌលច្បាប់ រួមទាំងកម្មវិធីក្រោមកិច្ចសហប្រតិបត្តិការណ៍ដៃគូអន្តរជាតិ និង ធ្វើការបោះជំរុំសិក្សានៅខេត្ត-ក្រុងណាមួយ បន្ទាប់មកធ្វើសិស្សទាំងនោះត្រូវប្រលងទទួលយក *វិញ្ញាបនបត្រសម្បទាខាងវិជ្ជាជីវៈមេធាវី* ដើម្បីរៀបចំធ្វើសច្ចាប្រណិទាន និង អនុវត្តកម្មវិធីចុះកម្មសិក្សាជា **មេធាវីកម្មសិក្សា** រយៈពេល១២ខែ និងចុងក្រោយត្រូវត្រលប់មកសិក្សានៅមជ្ឈមណ្ឌលលើកម្មវិធីរៀបចំជាពិសេសរយៈពេល៣ខែ ទើបចប់ជាស្ថាពរ។

បន្ទាប់ពីអនុវត្តកម្មវិធីរយៈពេល២ឆ្នាំខាងលើ ចប់សព្វគ្រប់ក្រុមប្រឹក្សាគណៈមេធាវីនឹងអនុមត័ ផ្តល់នូវសម្បទាបំពេញសិទ្ធជាមេធាវីពេញសិទ្ធ និងចុះបញ្ជីក្នុងបញ្ជីសមាជិកមេធាវី ។

## កម្មវិធីលំអិតសិក្សារយៈពេល២ឆ្នាំ សំរាប់សិស្សមេធាវីជំនាន់១០ ឆ្នាំសិក្សា ២០០៩-២០១១

## ១. កម្មវិធីសិក្សារយៈពេល៩ខែ

### ១.១. មុខវិជ្ជាចំបងត្រូវរៀនឆ្នាំទី១

| ល.រ | មុខវិជ្ជា | ចំនួនម៉ោង |
|---|---|---|
| ១. | ការធ្វើបទបង្ហាញកម្មវិធីសិក្សាដល់សិស្ស | ០៣ |
| ២. | ច្បាប់លក្ខន្តិកៈ-ក្រមសិលធម៌ និងការទទួលខុសត្រូវរបស់មេធាវី | ២៤ |
| **៣.** | **ក្រមរដ្ឋប្បវេណី (សរុប៨៤ម៉ោង)** | |
| ក.១. | បទបញ្ញត្តិទូទៅ | ០៣ |
| ក.២. | បុគ្គល | ០៩ |
| ក.៣. | សិទ្ធិប្រត្យក្ស | ១២ |
| ក.៤. | កាតព្វកិច្ច | ១៥ |
| ខ.១. | ប្រភេទនៃកិច្ចសន្យាសំខាន់ៗ | ១២ |
| ខ.២. | ការធានា | ១២ |
| ខ.៣. | ញាតិ | ០៩ |
| ខ.៤. | សន្តតិកម្ម | ១២ |
| **៤.** | **ក្រមនីតិវិធីរដ្ឋប្បវេណី (សរុប ៧៨ម៉ោង)** | |
| ក.១. | ការពន្យល់ទូទៅ ពីក្រមនីតិវិធី រដ្ឋប្បវេណី | ០៦ |
| ក.២. | ប្រធាននៃបណ្តឹង | ០៦ |
| ក.៣. | នីតិវិធីបណ្តឹងនៃការជំនុំជម្រះ លើកទីមួយ - ការដាក់ពាក្យបណ្តឹង | ១២ |
| ក.៤. | នីតិវិធីបណ្តឹងនៃការជំនុំជម្រះលើក ទីមួយ - ការជំនុំជម្រះលើបណ្តឹង | ១២ |
| ក.៥. | នីតិវិធីបណ្តឹងនៃការជំនុំជម្រះ លើកទីមួយ - ល័ក្ខខ័ណ្ឌបណ្តឹង | ០៣ |
| ខ.១. | នីតិវិធីបណ្តឹងនៃការជំនុំជម្រះលើក ទីមួយ - ការបញ្ចប់បណ្តឹង | ១២ |
| ខ.២. | នីតិវិធីបណ្តឹងនៃការជំនុំជម្រះលើក ទីមួយ-ភាពមានកម្មវត្ថុច្រើន និងភាពមានប្រធានច្រើននាក់ក្នុងបណ្តឹង | ០៩ |
| ខ.៣. | នីតិវិធីនៃការជំនុំជម្រះទៅតុលាការជាន់ខ្ពស់ និងនីតិវិធីនៃការជំនុំ ជម្រះសាជាថ្មី | ០៦ |
| ខ.៤. | ការអនុវត្តដោយបង្ខំ | ០៦ |
| ខ.៥. | ការចាត់ចែងរក្សាការពារ | ០៦ |
| **៥.** | **ក្រមព្រហ្មទណ្ឌ (សរុប ៦០ ម៉ោង)** | |
| ក.១. | គោលការណ៍ទូទៅ | ០៣ |
| ក.២. | អាជ្ញាយុកាលនៃទោស -បទល្មើស | ១២ |
| ក.៣. | ទោសបញ្ញាតិ លើកលែងបន្ធូរបន្ថយទោស | ០៩ |
| ខ.១. | ធាតុផ្សំបទល្មើស - បទល្មើសប៉ះពាល់ ដល់បុគ្គល | ០៩ |
| ខ.២. | ធាតុផ្សំបទល្មើស-បទល្មើសប៉ះពាល់ដល់ ទ្រព្យសម្បត្តិ | ០៩ |
| ខ.៣. | ធាតុផ្សំបទល្មើស -បទល្មើសប៉ះពាល់ ដល់សិទ្ធ-កម្មសិទ្ធបញ្ញា | ០៩ |
| ខ.៤. | ប្រៀបធៀបបទល្មើសប្រហាក់ប្រហែលគ្នា | ០៩ |
| **៦.** | **ក្រមនីតិវិធីព្រហ្មទណ្ឌ (សរុប ៨១ម៉ោង)** | |
| ក.១. | គោលការណ៍ទូទៅ នៃក្រមនីតិវិធី ព្រហ្មទណ្ឌ | ០៣ |

| | | |
|---|---|---|
| ក.២. | តួនាទីនគរបាល និងភ្នាក់ងារ យុត្តិធម៌ | ១២ |
| ក.៣. | តួនាទីព្រះរាជអាជ្ញា-អគ្គព្រះរាជអាជ្ញា | ១២ |
| ក.៤. | ភស្តុតាង-ឆែងឆេរ-កោសលវិច័យ | ១២ |
| ក.៥. | ចៅក្រមស៊ើបអង្កេត-សភាស៊ើបសួរ | ១២ |
| ខ.១. | ឃុំខ្លួនបណ្ដោះអាសន្ន ការដាក់ត្រួតពិនិត្យនៅតុលាការ | ០៩ |
| ខ.២. | នីតិវិធីជំនុំជំរះ- បណ្ដឹងឧបាស្រយ័ | ១២ |
| ខ.៣. | ការធ្វើបត្យាប័ន | ០៩ |
| ៧. | វិវាទការងារ | ១៥ |
| ៨. | វិវាទរដ្ឋបាល | ១៥ |
| ៩. | វិវាទដីធ្លី | ១៥ |
| ១០. | **វិវាទពាណិជ្ជកម្ម ( សរុប ៥៧ម៉ោង)** | |
| ក. | ការជំរះបញ្ជី-បន្សុតកម្ម | ១២ |
| ខ. | វិវាទកម្មសិទ្ធបញ្ញា | ១២ |
| គ. | បញ្ហាពន្ធដា និងសារពើពន្ធ | ១២ |
| ឃ. | គណនេយ្យ | ១២ |
| ១១. | ពិតមានវិទ្យា កំព្យូទ័រ ( សិក្សាបែងចែកជាក្រុម២) | ១៨ |
| ១២. | សិទ្ធិមនុស្ស-លិខិតតូបករណ៍អន្តរជាតិ-សិទ្ធកុមារ | ១៥ |
| | **ចំនួនម៉ោងសរុប** | **៤៥៦** |

**១.២. មុខវិជ្ជាបច្ចេកទេសនៅមណ្ឌលច្បាប់ត្រូវរៀនចែកជា២ក្រុម កម្មវិធីក្នុង១ក្រុមៗមាន :**

| ល.រ | មុខវិជ្ជា | ចំនួនម៉ោង |
|---|---|---|
| **១.** | **បច្ចេកទេសការពារក្ដី រដ្ឋប្បវេណី** | |
| ក. | ការសិក្សាសំនុំរឿងតាមរយៈសម្ភាសន៏កូនក្ដី | ០៩ |
| ខ. | ការបង្កើតរចនាសម្ពន្ធ័នៃសំនុំរឿង ដោយផ្អែកលើអង្គហេតុចុងក្រោយ | ១២ |
| គ. | ការធ្វើសេចក្ដីព្រៀងលើពាក្យបណ្ដឹង | ០៩ |
| ឃ. | ការវិភាគបញ្ហាក្នុងវិវាទសំនុំរឿង | ០៩ |
| ង. | ការរៀបចំក្នុងនីតិធីត្រៀមសំរាប់ទាញ ហេតុផលដោយផ្ទាល់មាត់ | ១២ |
| ច. | ការរៀបចំការទាញហេតុផលដោយ ផ្ទាល់មាត់ - ការពិនិត្យភស្តុតាង | ១២ |
| ឆ. | ការធ្វើសេចក្ដីព្រាងលើការអះអាងចុងក្រោយ | ០៩ |
| **២.** | **បច្ចេកទេសការពារក្ដី ការវិភាគច្បាប់ និង ការសរសេរញត្តិ រឿងព្រហ្មទណ្ឌ** | |
| ក. | ទ្រឹស្ដី ការពារ | ១២ |
| ខ. | ការសម្ភាសន៏កូនក្ដី និង សាក្សី និងការរៀបចំ រឿងក្ដី | ១២ |
| គ. | វិធាន និង របៀបប្រើប្រាស់ភស្តុតាង | ១២ |
| ឃ. | ការផ្ដើមការពារ | ០៦ |
| ង. | ការសរសេរញត្តិ និង ការវិភាគច្បាប់ | ០៦ |
| ច. | ការសួរសាក្សីរបស់ខ្លួនផ្ទាល់ និងសួរសាក្សី របស់ភាគីម្ខាងទៀតនៅពេលសវនាការ | ១២ |
| ឆ. | សេចក្ដីសន្និដ្ឋានការពារ | ០៩ |
| **៣.** | **ការរៀបចំ និង បង្កើត ការិយាល័យ** | |
| ក. | ការរៀបចំ និង គ្រប់គ្រង ការិយាល័យ | ០៣ |
| ខ. | ការរៀបចំ និង រក្សាទុកឯកសារ | ០៣ |
| គ. | ការទទួលកូនក្ដី | ០៣ |
| ឃ. | គណនេយ្យ | ០៣ |
| **៤.** | **ការទស្សនកិច្ចនៅតាមស្ថាប័នដែលពាក់ពន្ធ័** | |
| ក. | ទស្សនកិច្ចសិក្សានៅសាលាដំបូង | ០៦ |
| ខ. | ទស្សនកិច្ចសិក្សានៅពន្ធធានាគារ | ០៦ |
| គ. | ទស្សនកិច្ចសិក្សានៅសាលាឧទ្ធរណ៍ | ០៦ |
| ឃ. | ទស្សនកិច្ចសិក្សានៅតុលាការកំពូល | ០៦ |
| **៥.** | **ការធ្វើសវនាការសាកល្បង** | |
| ក. | សវនាការសាកល្បង-ព្រហ្មទណ្ឌ១ករណី | ១២ |
| ខ. | សវនាការសាកល្បង-រដ្ឋប្បវេណី១ករណី | ១២ |
| | **ចំនួនម៉ោងសរុបក្នុង១ក្រុម** | **២០១** |

**១.៣. មុខវិជ្ជាក្រោមកិច្ចសហប្រតិបតិការណ៏ដៃគូអន្តរជាតិ**

| ល.រ | មុខវិជ្ជា | ចំនួនម៉ោង |
|---|---|---|
| ១. | រដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី | ១៥ |
| ២. | ក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ | ២០ |
| ៣. | ឧបករណ៏អន្តរស្ដីពីសិទ្ធមនុស្ស | ២០ |
| ៤. | ការដោះស្រាយក្រៅប្រពន្ធ័តុលាការ | ២០ |
| ៥. | ពាណិជ្ជកម្មអន្តរជាតិ -វាក្យសព្ទ័ពាណិជ្ជកម្ម អន្តរជាតិ | ២០ |
| ៦. | ការសរសេរកិច្ចសន្យា | ២០ |
| ៧. | សិទ្ធកុមារ | ២០ |
| | **ចំនួនម៉ោងសរុប** | **១៣៥** |

**១.៤. កម្មវិធីពង្រឹងសមត្ថភាព – ការបោះជុំរុំ** *(Summer Camp)*

កម្មវិធីនេះ ធ្វើឡើងបន្ទាប់ពីការសិក្សា៩ខែខាងលើបានចប់សព្វគ្រប់ដោយសិស្សមេធាវីត្រូវចុះសិក្សាពី ទិដ្ឋភាពជាក់ស្ដែងនៅតំបន់-ខេត្តណាមួយ ជាពិសេសនៅពន្ធធានាគារ-តុលាការ និងធ្វើសិក្ខាសាលាទៅសាធារណៈជនទូទៅដោយធ្វើបទឧទ្ទេសនាម និងផ្ដល់ការប្រឹក្សាដោយសិស្សមេធាវីទាំងនោះ ។

**១.៥. ការប្រលងយកវិញ្ញាបនបត្រសម្បទាខាងវិជ្ជាជីវៈមេធាវី**

បន្ទាប់ការសិក្សាកម្មវិធី៩ខែចប់នៅមជ្ឈមណ្ឌលហើយ សិស្សមេធាវីត្រូវប្រលងបញ្ចប់ការសិក្សាស្ថាពរ ទទួលយកវិញ្ញាបនបត្រសម្បទាខាងវិជ្ជាជីវៈមេធាវី ។ សិស្សដែលបានប្រលងជាប់ស្ថាពរ ត្រូវរៀបចំសំនុំបែបបទទៅគណៈមេធាវីសុំធ្វើកម្មសិក្សាជាមេធាវីកម្មសិក្សារយៈពេល១ឆ្នាំតាមច្បាប់ ។

## ២. កម្មវិធីធ្វើជាមេធាវីកម្មសិក្សារយៈពេល១២ខែ

បន្ទាប់ពីបានស្បថរួចមក សិស្សមេធាវីត្រូវធ្វើកម្មសិក្សាដោយស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈមេធាវី និង មជ្ឈមណ្ឌលផ្នែកការបណ្ដុះបណ្ដាល ។ សិស្សមេធាវីត្រូវធ្វើរបាយការណ៏ និងការពាររបាយការណ៏ខ្លួនតាមការចាំបាច់នៅពេលចប់កម្មសិក្សា ដើម្បីបំពេញសិទ្ធជាមេធាវី ។

## ៣. កម្មវិធីសិក្សាពិសេសរយៈពេល៣ខែ

កម្មវិធីនេះធ្វើឡើងជាពិសេសសំរាប់សិស្សមេធាវី ក្រោយពីបានជួបការលំបាកក្នុងការអនុវត្តន៏ជាក់ស្ដែងកន្លងមក នៅពេលចុះកម្មសិក្សានោះ កម្មវិធីរៀបចំដោយសិក្សាលើការអនុវត្តជាក់ស្ដែងជាចំបង ។

## ៤. ការបំពេញសិទ្ធជាមេធាវី

ក្រោយពីរៀនចប់សព្វគ្រប់ ធ្វើកម្មសិក្សារួចមក ក្រុមប្រឹក្សាគណៈមេធាវី នឹងសំរេចបំពេញសិទ្ធឱ្យជាមេធាវីពេញសិទ្ធ បើសិនជាមេធាវីកម្មសិក្សារូបនោះបានបំពេញលក្ខណៈត្រឹមត្រូវសមស្រប និងពេញសមត្ថភាពហើយ ។

*រៀបចំ-សង្ខេបកម្មវិធីដោយ មេធាវី **អិន វ៉ាន ឈន***
*អគ្គលេខាធិការមជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈមេធាវី*